# ខ្លឹមសារសង្ខេប

## ការពិពណ៌នាពីគម្រោង

គម្រោងការងារល្អប្រសើរដោយការផ្តល់ជំនាញនៅប្រទេសកម្ពុជា នឹងជួយគាំទ្រការកសាងជំនាញដល់កម្លាំងពលកម្មដែលមានស្រាប់ និងកម្លាំងពលកម្មថ្មី ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ ការផ្តល់ពត៌មានទីផ្សារការងារ(LMI) និង ការផ្តល់ប្រឹក្សាយោបល់ពាក់ព័ន្ធនឹងការងារដែលល្អប្រសើរ។ គម្រោងនេះនឹងផ្តោតលើការផ្តល់ជំនាញដែលមានគុណភាពស្របតាមតម្រូវការរបស់ទីផ្សារការងារ ដែលជាបញ្ហាប្រឈមពាក់ព័ន្ធនឹងការកង្វះខាតជំនាញនៅក្នុងកម្លាំងពលកម្ម។ ម្យ៉ាងទៀត គម្រោងនេះមានសមាសភាពចំនួន៤ដូចជា៖ ១)ការលើកម្ពស់ជំនាញដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ២)ការផ្តល់ពត៌មាន និងការប្រឹក្សាយោបល់ពាក់ព័ន្ធនឹងការងារដែលល្អប្រសើរ ៣)ការគ្រប់គ្រងគម្រោង និង ៤)សមាសភាពឆ្លើយតបនឹងភាពអាសន្នដែលពាក់ព័ន្ធ(CERC)។

## គោលបំណងនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម(ESMF) មានបង្ហាញ គោលការណ៍ ច្បាប់ គោលការណ៍ណែនាំ និងនីតិវិធី ក្នុងការវាយតម្លៃហេតុប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គមគម្រោង។ ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនេះក៏មានរៀបរាប់ពីវិធានការណ៍កាត់បន្ថយ និងបញ្ចៀសហានិភ័យ ព្រមទាំងកញ្ចប់ថវិកាសម្រាប់ភ្នាក់ងារ និងអង្គភាពធ្វើការអនុវត្ត ស្របតាមក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក(ESF)។

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមរួមបញ្ចូលដូចតទៅ៖

- ពត៌មានសង្ខេប អំពីគម្រោង
- ការរៀបរាប់ក្របខណ្ឌបទបញ្ញត្តិថ្នាក់ជាតិដែលពាក់ព័ន្ធនឹងគម្រោង និងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ព្រមទាំងរៀបរាប់ចន្លោះខ្វះខាតផងដែរ
- ហេតុប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គម ព្រមទាំងវិធានការកាត់បន្ថយ
- នីតិវិធីនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងការជ្រើសរើស(Screening) និងរៀបចំឯកសារស្តីពី វិធីសាស្រ្តគ្រប់គ្រងបរិស្ថាន និងសង្គម(ESCoP) ឬផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP)ព្រមទាំងរួមបញ្ចូលការរៀបចំស្ថាប័ន
- ការរៀបចំស្ថាប័ន និងការវាយតម្លៃសមត្ថភាពក្នុងការអនុវត្តក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម និងឧបករណ៍ផ្សេងទៀត
- ការពិភាក្សាពិគ្រោះយោបល់ និងការចូលរួមពីអ្នកពាក់ព័ន្ធ
- យន្តការដោះស្រាយបណ្តឹងតវ៉ា
- ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍
- កញ្ចប់ថវិកា។

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម(ESMF) មានភ្ជាប់នូវ លក្ខខណ្ឌដែលមិនមានសិទ្ធ ទម្រង់សម្រាប់ការជ្រើសរើស និងកំណត់វិសាលភាព ការវាយតម្លៃសង្គមឆាប់រហ័ស ផែនការគ្រប់គ្រងសំណល់អេឡិចត្រូនិច នីតីវិធីគ្រប់គ្រងពលកម្មការងារ ក្រមវិជ្ជាជីវៈ វិធីសាស្រ្តគ្រប់គ្រងបរិស្ថាន និងសង្គម( ESCoP) មាតិកានៃផែនការគ្រប់គ្រងបរិស្ថាន និងសង្គម សមាសភាពឆ្លើយតប

នឹងភាពអាសន្នដែលពាក់ព័ន្ធ(CERC) ការណែនាំស្តីពីការឆ្លើយតបនឹងភាពអាសន្ន និងផ្សេងៗទៀតនៅក្នុងឧបសម្ព័ន្ធនៃក្របខណ្ឌនេះ។

ឯកសារក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម(ESMF) ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ(SEP) និង ផែនការប្តេជ្ញាចិត្តខាងផ្នែកបរិស្ថាន និងសង្គម(ESCP) ត្រូវបានរៀបចំឡើង និងត្រូវបានពិគ្រោះយោបល់ជាសាធារណ ព្រមទាំងផ្សព្វផ្សាយក្នុងខែមិថុនា ឆ្នាំ ២០២៣។

**វិធានការណ៍កាត់បន្ថយ និងហេតុប៉ះពាល់ចម្បងៗ**

ដោយសារទីតាំងនៃវិទ្យាស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងមជ្ឈមណ្ឌលប្រឹក្សាយោបល់លើវិស័យការងារដែលនឹងត្រូវជ្រើសរើស មិនទាន់បានកំណត់នៅក្នុងដំណាក់កាលរៀបចំគម្រោង វាជាការលំបាកក្នុងការផ្តល់ទិន្នន័យលម្អិតពាក់ព័ន្ធនឹងហេតុប៉ះពាល់និងហានិភ័យបរិស្ថាន និងសង្គមដែលបណ្តាលមកពីគម្រោង។ យ៉ាងណាក៏ដោយយោងតាមការអនុវត្តគម្រោងដទៃដែលមានលក្ខណបរិបទបរិស្ថាន និងសង្គមប្រហាក់ប្រហែលគ្នា ការវាយតម្លៃបរិស្ថាននិងសង្គមឆាប់រហ័ស និងការជួបពិភាក្សាជាមួយអ្នកពាក់ព័ន្ធត្រូវបានធ្វើឡើងពីខែមេសាដល់ខែឧសភា ឆ្នាំ២០២៣។ មួយវិញទៀត សិក្ខាសាលាពិគ្រោះយោបល់ត្រូវបានធ្វើឡើងនៅខែមិថុនាឆ្នាំ ២០២៣ដើម្បីរៀបចំគម្រោងនេះ។ តាមរយសកម្មភាពទាំងនេះនឹងជួយដល់ការសន្មត់ រួមទាំងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពនៅពេលវិទ្យាស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងមជ្ឈមណ្ឌលប្រឹក្សាយោបល់លើវិស័យការងារ ត្រូវបានជ្រើសរើស និងកំណត់។

យោងតាមបទដ្ឋានទី១ របស់ធនាគារពិភពលោក គម្រោងនេះនឹងអនុវត្តតាមលំដាប់លំដោយនៃវិធានការណ៍ដូចខាងក្រោម៖

- ការការពារ និងការជៀសវាងហានិភ័យ និងហេតុប៉ះពាល់
- ប្រសិនបើមិនអាចជៀសវាងបាន ការកាត់បន្ថយហានិភ័យ និងហេតុប៉ះពាល់អោយស្ថិតក្នុងកម្រិតអប្បបរមាដែលអាចទទួលបាន
- ក្រោយពីការកាត់បន្ថយហានិភ័យ និងហេតុប៉ះពាល់អោយស្ថិតក្នុងកម្រិតអប្បបរមា វិធានការកាត់បន្ថយត្រូវអនុវត្ត
- ប្រសិនបើហេតុប៉ះពាល់នូវតែមាន សំណងត្រូវបានធ្វើឡើងដោយផ្អែកលើលទ្ធភាពបច្ចេកទេស និងហិរញ្ញវត្ថុ។

អ្នកទទួលផលពីគម្រោងអាចជាបុគ្គល ដែលមកពីកម្លាំងពលកម្មដែលមានស្រាប់ និងកម្លាំងពលកម្មដែលនឹងកើតមានក្នុងប្រទេសកម្ពុជាដែលចូល ឬបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្វែងរកឱកាសដើម្បីទទួលបានការងារដែលល្អប្រសើរ។ ទាំងកម្លាំងពលកម្មដែលមានស្រាប់និងកម្លាំងពលកម្មដែលនឹងកើតមាន នឹងអាចទទួលបានពត៌មានទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាល និងសេវាកម្មទីផ្សារការងារដែលគាំទ្រពីគម្រោង។ អ្នកទទួលផលពីគម្រោងនឹងមានជម្រើសក្នុងការទទួលបានការវាយតម្លៃ និងទទួលបានវិញ្ញាប័នបត្រទៅតាមកម្រិតផ្សេងៗ ក៏ដូចជាទទួលបានការងារល្អប្រសើរ និងទទួលបានប្រាក់សន្សំច្រើនជាងមុន។ ម្យ៉ាងវិញទៀត គម្រោងនឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ តាមរយសកម្មភាពកសាងសមត្ថភាពដល់ ក)បុគ្គលិកជាន់ខ្ពស់ គ្រូបង្រៀន គ្រូបង្គោល នៃវិទ្យាស្ថានដែលគម្រោងនឹងជ្រើសរើស និងកូនសិស្ស អោយមានចំណេះដឹង និងជំនាញកាន់តែប្រសើរ ខ)និយោជកក៏ទទួលអត្ថប្រយោជន៍ពីកម្លាំងការងារដែលមានការលើកកំពស់ជំនាញ និងវគ្គបណ្តុះបណ្តាលស្របតាមតម្រូវការ គ)អ្នកស្វែងរកការងារ ទទួលបានការប្រឹក្សាយោបល់ទាក់ទងនឹងការងារ ឃ)មន្ត្រីរាជការ ជំនាញការ និងបុគ្គលិកមកពីមជ្ឈមណ្ឌលផ្តល់ប្រឹក្សា ង)អ្នកប្រើប្រាស់ប្រព័ន្ធពត៌មានគ្រប់គ្រងការងារ។គម្រោងនឹងលើកកំពស់ក្រុមដែលងាយរងគ្រោះ ដូចជាស្ត្រី និងអ្នកដទៃ។

ហេតុប៉ះពាល់សង្គមរបស់គម្រោងត្រូវបានវាយតម្លៃ គឺស្ថិតនៅកំរិតមធ្យម (Moderate) ។ យោងតាមការងារជួសជុល និងការងារសោងសង់អគារ គម្រោងនេះគួរដោះស្រាយហេតុប៉ះពាល់ និងហានិភ័យដែលមានសក្ដានុពលមានដូចជា ក)សុវត្ថិភាព និងសុខភាពកម្មករ និងបុគ្គលិក (OHS) ខ)ការហូរចូលពលកម្មក្នុងចំនួនតូច គ)ការរំលោភ និងការធ្វើអាជីវកម្មផ្លូវភេទ ការបៀតបៀនកេរខ្មាស់ និងអំពើហឹង្សាលើកុមារ ឃ)ពលកម្មកុមារ និង ង)ពលកម្មការងារដែលបង្ខិតបង្ខំ។ ម៉្យាងទៀត ការរើសអើងនិងការមិនគិតគូក្រុមដែលងាយរងគ្រោះ ក៏ជាហានិភ័យដែលអាចកើតឡើងពីសកម្មភាពគម្រោង មិនថាការងារជួសជុលកែលម្អ។

ចំណែកហានិភ័យផ្នែកបរិស្ថានរបស់គម្រោងនេះ គឺនៅកម្រិត មធ្យម នៅដំណាក់នេះ ដែល ហេតុប៉ះពាល់បរិស្ថានចម្បងៗពាក់ព័ន្ធនឹង ក)ការបញ្ចេញសំណល់ក៏ដូចជាសំណល់អេឡិចត្រូនិច និងហានិភ័យលើសុវត្ថិភាព និងសុខភាពកម្មករបណ្ដាលមកពីការផ្លាស់ប្ដូរឧបករណ៍បច្ចេកវិទ្យា នៅតាមមណ្ឌលសិក្សា និងប្រព័ន្ធព័ត៌មានទីផ្សារការងារ (LMIS) ខ)សំឡេងរំខាន ធូលី ការលេចសាយភាយ តិចតួច សំណល់និងជីល្បាប់ ក៏ដូចជាហានិភ័យពាក់ព័ន្ធនឹងសុវត្ថភាព និងសុខភាពកម្មករក្នុងពេលសាងសង់ និងជួសជុលអគារស្ថិតនៅវិទ្យាស្ថានអប់រំ បណ្ដុះបណ្ដាល បច្ចេកទេស និងវិជ្ជាជីវៈ និងមជ្ឈមណ្ឌលប្រឹក្សាយោបល់លើវិស័យការងារដែលជ្រើសរើសដោយគម្រោង។ សំណល់ដែលចេញពីការដ្ឋានសំណង់រួមមាន សំណល់គ្រោះថ្នាក់ដូចជា Asbestos ដែលផ្ទុកសារជាតុលោហៈ និងថ្នាំលាបដែលមានសារជាតុបារត។

យោងតាមក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក(ESF) និងបទដ្ឋានបរិស្ថាន និងសង្គម(ESS) គម្រោងបានរៀបចំវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលពាក់ព័ន្ធដើម្បីដោះស្រាយហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ដើម្បីធានាការអនុវត្តវិធានការណ៍ប្រកបដោយប្រសិទ្ធិភាព គម្រោងបានរៀបចំឧបករណ៍ពីរដែលជាឯកសារក្របខណ្ឌបរិស្ថាន និងសង្គម រួមមាន វិធីសាស្ត្រគ្រប់គ្រងបរិស្ថាន និងសង្គម (ESCoP) សម្រាប់ការងារជួសជុល និងកែលម្អ និងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP)សម្រាប់ការងារសាងសង់អគារថ្មី ហើយឯកសារទាំងនេះត្រូវបានប្រើប្រាស់ក្នុងការគ្រប់គ្រងហានិភ័យនានាក្នុងវដ្ដនៃគម្រោងទាំងមូល។ ឧបករណ៍(ESF)រួមបញ្ចូល សមាសភាគផ្សេងៗដូចជាដំណើរការជ្រើសរើស(Screening)ឬកំណត់ហានិភ័យបរិស្ថាន និងសង្គម យន្តការដោះស្រាយបណ្ដឹងតវ៉ា ផែនការចូលរួមពីភាគីពាក់ព័ន្ធ នីតិវិធីត្រួតពិនិត្យ និងរាយការណ៍។ការប្រើប្រាស់ឧបករណ៍(ESF) ក្នុងគោលបំណងធានារាល់សកម្មភាពគម្រោងធ្វើឡើងប្រកបដោយគិតគូ និងការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន និងសង្គម ហើយរាល់ហេតុប៉ះពាល់ត្រូវបានកំណត់ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព។

**<u>នីតិវិធីស្ដីពីក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម</u>**

គោលបំណងរបស់ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម គឺដើម្បីគ្រប់គ្រងហានិភ័យ និងហេតុប៉ះពាល់បរិស្ថាន និងសង្គម ដោយការបង្កើតអោយមានឯកសារណែនាំក្នុងការប្រាប់ដល់អង្គភាពគ្រប់គ្រងគម្រោង និងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ក៏ជាឯកសារណែនាំដល់ដំណើរការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម នៅពេលដែលអនុគម្រោងត្រូវបានកំណត់ជាក់ច្បាស់។

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមធានាថា៖

- អនុគម្រោងនឹងគិតគូពី បញ្ហាបរិស្ថាន និងសង្គមចម្បងៗ ជាពិសេសក្រុមមនុស្សផ្សេងៗគ្នាដែលទទួលផលដោយផ្ទាល់ទាំងវិជ្ជមាន និងអវិជ្ជមាន
- អនុគម្រោងនឹងគិតគូពីបញ្ហាបរិស្ថាន យេនឌ័រ និងសង្គមវប្បធម៌ដែលអាចកើតមាននៅទីតាំងដែលអនុគម្រោងស្ថិតនៅ

- ឧបករណ៍បរិស្ថាន និងសង្គមដែលរៀបចំឡើងស្របតាមក្របខណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក និងច្បាប់ និងគោលនយោបាយថ្នាក់ជាតិ
- អនុគម្រោងនឹងអនុវត្តតាមអ្វីដែលមានរៀបរាប់នៅក្នុងឯកសារនេះក៏ដូចជាលំដាប់នៃវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម
- យន្តការជ្រើសរើសត្រូវបានប្រើប្រាស់ដើម្បីកំណត់ពីហានិភ័យ និងហេតុប៉ះពាល់បរិស្ថាន និងសង្គមនៅពេលទីតាំងអនុគម្រោងត្រូវបានកំណត់
- ការបង្កើតអោយមាននីតិវិធី និងការទទួលខុសត្រូវក្នុងការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមរៀបរាប់ពីនីតិវិធីនៃការជ្រើសរើស និងការកំណត់វិសាលភាព ក៏ដូចជាជំហានលម្អិតក្នុងការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងករណីត្រូវការ ។ ការរៀបចំឯកសារនេះត្រូវការពត៌មានរួមមាន ការទទួលខុសត្រូវ តម្រូវការកសាងសមត្ថភាព និងវគ្គបណ្ដុះបណ្ដាលសម្រាប់បុគ្គលិកគម្រោងដែលទទួលបន្ទុកក្នុងការត្រួតពិនិត្យការអនុវត្តផែនការការគ្រប់គ្រងបរិស្ថាន និងសង្គម។ ការរៀបចំស្ថាប័នសម្រាប់គម្រោងនៅក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈថ្នាក់ជាតិ ក៏ដូចជាអ្នកជំនាញការ និងក្រុមហ៊ុនម៉ៅការសាងសង់ គឺមានរៀបរាប់នៅផ្នែកទី៦នៃរបាយការណ៍នេះ។

**ការពិគ្រោះយោបល់ និងការចូលរួមពីភាគីពាក់ព័ន្ធ**

គម្រោងនឹងរៀបចំការពិគ្រោះយោបល់ និងការចូលរួមពីភាគីពាក់ព័ន្ធដូចដែលមានចែងនៅក្នុងផែនការការចូលរួមរបស់អ្នកពាក់ព័ន្ធរបស់គម្រោងដែលឯកសារនេះបានរៀបចំនៅខែមេសាឆ្នាំ ២០២៣។ ផែនការការចូលរួមរបស់អ្នកពាក់ព័ន្ធ គឺធានាដល់ភាគីអ្នកពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោល នឹងត្រូវចូលរួមគម្រោងគ្រប់ដំណាក់ឬជំហានរបស់កម្រោង។ គម្រោងទទួលស្គាល់ពីតម្រូវការនៃការតំណាងពីភាគីពាក់ព័ន្ធនិងស្វែងរកជាតុចូល។ ផែនការចូលរួមពីភាគីអ្នកពាក់ព័ន្ធ ក៏ផ្ដោតលើតួនាទីរបស់ស្ត្រី និងក្រុមងាយរងគ្រោះនៅក្នុងដំណើរការពិគ្រោះយោបល់។ ផែនការចូលរួមពីភាគីអ្នកពាក់ព័ន្ធមានគោលបំណងក្នុងការឆ្លើយតប និងមានការចូលរួមពីក្រុមងាយរងគ្រោះ ដូចជាជនជាតិដើមភាគី ដើម្បីធានាពួកគាត់អាចទទួលផលវិជ្ជមានពីគម្រោង។ គម្រោងក៏ទទួលស្គាល់ពីសារសំខាន់ពីការចូលរួមពីជនរងផលប៉ះពាល់តាមរយការអនុវត្តវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ កម្មវិធីសុវត្ថិភាព និងសុខភាពកម្មករ ក៏ដូចជាការត្រួតពិនិត្យសកម្មភាពគម្រោងជាបន្តបន្ទាប់។

**យន្តការដោះស្រាយបណ្ដឹងតវ៉ា**

យន្តការដោះស្រាយបណ្ដឹងតវ៉ាត្រូវបានរៀបចំឡើងដើម្បីដោះស្រាយការព្រួយបារម្ភឬកង្វល់អោយទាន់ពេលវេលា តាមយន្តការយោគយល់គ្នាផ្អែកតាមភាពសមស្រប និងមិនអស់កម្រៃ។ បណ្ដឹងតវ៉ាអាចត្រូវបានធ្វើរចេញប្រសិនបើមានការរកឃើញបញ្ហាដែលកើតចេញពីគម្រោងទៅលើសហគមន៍ បរិស្ថាន ឬក៏គុណភាពនៃជីវិត។ អ្នកពាក់ព័ន្ធផ្សេងទៀតក៏អាចផ្ញើរមតិយោបល់ និងសំណូមពរផងដែរ។ យន្តការដោះស្រាយបណ្ដឹងតវ៉ានេះមានរៀបរាប់លម្អិតនៅក្នុងផែនការចូលរួមពីអ្នកពាក់ព័ន្ធរបស់គម្រោង ក៏ដូចជាផ្នែកទី៨នៃរបាយការណ៍នេះ។

**ការត្រួតពិនិត្យតាមដាន និងការរៀបចំរបាយការណ៍**

ការត្រួតពិនិត្យតាមដាន ជាវិធីសាស្ត្រមួយ ដើម្បីធានាពីប្រសិទ្ធភាពនៃការអនុវត្តវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់។ របាយការណ៍ត្រួតពិនិត្យតាមដានប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាសនឹងត្រូវរៀបចំឡើងដើម្បី៖

- ធ្វើអោយប្រសើរឡើងការអនុវត្តការគ្រប់គ្រងបរិស្ថាន និងសង្គម

- ធានាពីប្រសិទ្ធភាព និងគុណភាពនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- បង្កើតអោយមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមផ្អែកលើលទ្ធផល និងភស្តុតាង
- ផ្តល់អោយមានការរាយការណ៍ពីលទ្ធផលនៃការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

នៅដំណាក់កាលអនុវត្ត មន្ត្រីបង្គោលខាងផ្នែកបរិស្ថាន និងសង្គមរបស់អង្គភាពគ្រប់គ្រងគម្រោងនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើការត្រួតពិនិត្យផ្ទៃក្នុងជាប្រចាំខែលើប្រសិទ្ធិភាពនៃការអនុវត្តវិធានការណ៍កាត់បន្ថយដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។ របាយការណ៍ត្រួតពិនិត្យនឹងត្រូវបានពិនិត្យដោយអង្គភាពគ្រប់គ្រងគម្រោង និងត្រូវផ្ញើបន្តទៅធនាគារពិភពលោកដើម្បីពិនិត្យបន្ថែម។ មន្ត្រីបង្គោលខាងផ្នែកបរិស្ថាន និងសង្គមនឹងត្រូវបានជួយពិនិត្យដោយជំនាញការដែលជ្រើសរើសដោយអង្គភាពគ្រប់គ្រងគម្រោង។

មន្ត្រីបង្គោល និងជំនាញការទទួលបន្ទុកផ្នែកបរិស្ថាន និងសង្គមនឹងត្រួតពិនិត្យ ការអនុវត្តវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់ដែលមានចែងនៅក្នុង វិធីសាស្ត្រគ្រប់គ្រងបរិស្ថាន និងសង្គម(ESCoP) ឬផែនការគ្រប់គ្រងបរិស្ថាន និងសង្គម(ESMP) របស់ក្រុមហ៊ុនម៉ៅការសាងសង់ដែលស្ថិតនៅក្រោម វិទ្យាស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ទទួលបានជ័យលាភី។

មន្ត្រីបង្គោល និងជំនាញការទទួលបន្ទុកផ្នែកបរិស្ថាន និងសង្គម នឹងធ្វើការត្រួតពិនិត្យ ការដោះស្រាយបណ្តឹងតវ៉ា ដើម្បីធានាថាជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះផ្សេងទៀតអាចទទួលបានផលប្រយោជន៍ឬអត្ថប្រយោជន៍ ក៏ដូចជាការត្រួតពិនិត្យការអនុវត្តការពិភាក្សាពិគ្រោះយោបល់ និងសកម្មភាពផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ។ មួយវិញទៀតការត្រួតពិនិត្យការអនុវត្តវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់បរិស្ថាននិងសង្គមតាមរយ ESCoP/ESMP ក៏ត្រូវបានផ្តោតជាចម្បងផងដែរ។

**<u>ថវិកា</u>**

ការចំណាយលើការអនុវត្ត ESMF នឹងរាប់បញ្ចូលរៀបចំឧបករណ៍គ្រប់គ្រងបរិស្ថាន និងសង្គម ដោយរួមបញ្ចូល ថវិកាសម្រាប់បុគ្គលិក ការធ្វើដំណើរ ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ការបកប្រែកសារ និងវគ្គបណ្តុះបណ្តាល។ ថវិកាទាំងអស់នេះមានការពិនិត្យដោយធនាគារពិភពលោក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រមាណ ១៥០ ០០០ដុល្លាសហរដ្ឋអាមេរិច ដែលថវិកានេះក៏រួមបញ្ចូលថវិកាសម្រាប់ការអនុវត្តវិធានការណ៍កាត់បណ្ថយហេតុប៉ះពាល់ដែលមានចែងនៅក្នុង ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ប្រសិនបើមាន)។ កញ្ចប់ថវិកាគឺមានប្រភពពីធនាគារពិភពលោក និង ថវិកាបដិភាគពីដៃគូក្នុងការអនុវត្តគម្រោង។ ថវិកានេះត្រូវបានបង្ហាញ និងកែសម្រួលនៅពេលរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម។